ភ្នំពេញ ថ្ងៃទី ៨ មីនា ឆ្នាំ២០២១

សេចក្តីថ្លែងការណ៍រួម
នាឱកាសនារីអន្តរជាតិ ៨ មីនា ឆ្នាំ ២០២១ ក្រុមអង្គការសង្គមស៊ីវិល ស្នើទៅដល់រាជរដ្ឋាភិបាលកម្ពុជា អោយចាត់នូវវិធានការចាំបាច់ដើម្បីអនុវត្តសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុកអនុសញ្ញាស៊ីដ

យើងខ្ញុំតំណាងអោយក្រុមអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សមាគម សហជីព ដូចមានរាយនាមខាងក្រោម សូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវជំហ៊ានជាក់លាក់ដើម្បីអនុវត្តនូវអនុសាសន៍ដែលបានចែងនៅក្នុងសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុកអនុសញ្ញាស៊ីដ ដើម្បីលើកកម្ពស់សិទ្ធិមនុស្សរបស់ស្ត្រីនៅកម្ពុជា ។

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (NGO-CEDAW) និងអង្គការសង្គមស៊ីវិលជាដៃគូរ បានចេញផ្សាយនូវរបាយការណ៍តាមដានការអនុវត្តអនុសញ្ញា ស៊ីដ សម្រាប់ឆ្នាំ ២០២០ ។ របាយការណ៍នេះបានលើកយកនូវចំនុចជោគជ័យ និងបញ្ហាកង្វះចន្លោះ របស់រាជរដ្ឋាភិបាល ចំពោះការអនុវត្តអនុសញ្ញាលប់បំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (អនុសញ្ញាស៊ីដ) ។ របាយការណ៍នេះផងដែរក៏បានលើកឡើងនូវរបាយការណ៍វឌ្ឍនភាពមួយស្តីពីជំហ៊ាននានាដែលបានអនុវត្តកន្លងមក ក្នុងការអនុវត្តអនុសាសន៍ដែលមានចែងនៅក្នុងសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយ របស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុកអនុសញ្ញាស៊ីដ ឆ្នាំ ២០១៩ ។ សូមទាញយករបាយការណ៍ពេញលេញតាមរយៈគេហទំព័រ: ngocedaw.org/2020-cedaw-monitoring-report/

យោងតាមលទ្ធផលស្រាវជ្រាវរបស់យើងខ្ញុំ និងសំណើរសុំពីគណៈកម្មាធិការស៊ីដ អោយមានការដាក់បញ្ជូនរបាយការណ៍តាមដាននៅក្នុងខែវិច្ឆិការ ឆ្នាំ ២០២១ នេះ យើងខ្ញុំទាំងអស់គ្នាសូមធ្វើការស្នើដល់រដ្ឋាភិបាលកម្ពុជាអោយដាក់ចេញនូវជំហ៊ានចាំបាច់ជាអត្ថិភាពចំពោះបញ្ហាមួយចំនួនក្នុងការអនុវត្តអនុសញ្ញាស៊ីដ ដូចមានរាយខាងក្រោមនេះ៖

១. ទម្លាក់ចោលនូវសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ និងអនុក្រឹត្យថ្មីស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណែតជាតិ ដោយសេចក្តីព្រាងច្បាប់ និងអនុក្រិត្យថ្មីនេះអាចរំលោភលើសេរីភាពក្នុងការការសម្តែងចេញ និងសិទ្ធិឯកជនរបស់ស្ត្រី ហើយចាំបាច់ត្រូវធ្វើការប៉ាន់ប្រមាណផលប៉ះពាល់ទៅលើយេនឌ័រ មុនអនុម័តច្បាប់ថ្មីមុនពេលអនុម័តច្បាប់ថ្មី។

២. បែងចែកផ្តល់ថវិកាជាតិឱ្យបានគ្រប់គ្រាន់សម្រាប់ការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី៣ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ព្រមទាំងគោលនយោបាយសមភាពយេនឌ័រ ឱ្យមានប្រសិទ្ធិភាព។

៣. ធ្វើវិសោធនកម្មនិងពង្រឹងការអនុវត្តច្បាប់នានាដែលមានគោលបំណងលុបបំបាត់អំពើហិង្សាលើដៃគូស្និទ្ធស្នាល អំពើហិង្សាផ្លូវភេទទៅលើក្មេងស្រី និងរាល់ទម្រង់នៃអំពើហិង្សាផ្អែកលើយេនឌ័រ ជាពិសេសតាមរយៈការផ្តល់សេវាដែលមានការឆ្លើយតបតាមតម្រូវការរបស់ពួកគេ ដែលផ្តោតទៅលើសុខុមាលភាពផ្លូវកាយនិងផ្លូវចិត្តរបស់ជនរងគ្រោះ និងធានាឱ្យមានការទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះ។

៤. ដាក់ចេញនូវសកម្មភាពដើម្បីទប់ស្កាត់ និងលុបបំបាត់រាល់ការបៀតបៀន រាល់អំពើហឹង្សា និងទម្រង់ផ្សេងទៀតនៃការរើសអើងផ្អែកលើយេនឌ័រក្នុងពិភពការងារ តាមរយៈការដាក់ចេញនូវគោលនយោបាយជាតិដ៏រឹងមាំ និងផ្តល់សច្ចាប័នលើអនុសញ្ញា ILO លេខ ១៩០ ។

៥. បណ្តុះបណ្តាលដល់ភ្នាក់ងារសន្តិសុខទាំងអស់ដែលជួលដោយរដ្ឋ ឬរដ្ឋបាលរាជធានី ខេត្ត រួមមានអ្នកគ្រប់គ្រង និងអ្នកចាត់ចែងផ្ទាល់របស់ពួកគេ អំពីរបៀបនៃការប្រាស្រ័យទាក់ទងជាមួយស្ត្រីតាមបែបអហឹង្សា និងប្រកបដោយឥរិយាបថគិតគូរអំពីយេនឌ័រ។

សម្រាប់ការទំនាក់ទំនងបន្ថែមសូមទំនាក់ទំនងមកកាន់៖

១. អ្នកស្រី ជឹម ចាន់នាង, អគ្គលេខាធិការអង្គការ អិនជីអូ ស៊ី ដ, ទូរសព្ទ 012 668 853
២. អ្នកស្រី បុណ្យ រចនា, នាយិកាប្រតិបត្តិអង្គការក្លាហាន, ទូរសព្ទ 089 476 146
៣. អ្នកស្រី អ៊ូ សុភារី, អ្នកសម្របសម្រួលយុទ្ធនាការ នៃអង្គការអាក់សិនអេតកម្ពុជា 012 621 822

សេចក្តីថ្លែងការណ៍នេះត្រូវបានអនុម័តគាំទ្រដោយ៖

១. អង្គការ អាក់សិនអេតកម្ពុជា (ActionAid Cambodia)
២. សមាគមអ្នកបម្រើការងារតាមផ្ទះ (ADW)
៣. សមាគមគាំពារស្ត្រីងាយរងគ្រោះ (ASVW)

៤. អង្គការបន្ទាយស្រី (Banteay Srei)

៥. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

៦. សហជីពកម្មករចំណីអាហារនិងសេវាកម្មកម្ពុជា (CFSWF)

៧. សហភាពការងារកម្ពុជា(CLC)

៨. មជ្ឈមណ្ឌលកម្ពុជាដើម្បីព័ត៌មានឯករាជ្យ (CCIM)

៩. អង្គការកម្ពុជាដើម្បីសុខភាពនិងការអប់រំសហគមន៍ (CHEC)

១០. អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិនុស្ស លីកាដូ (LICADHO)

១១. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធ៌មនៅកម្ពុជា (ខុមព្រៃល)

១២. យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)

១៣. បណ្តាញ យេនឌ័រ និងអភិវឌ្ឍន៍កម្ពុជា (GADnet)

១៤. សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)

១៥. អង្គការក្លាហាន (Klahaan)

១៦. គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ (និកហ្វិក)

១៨. មជ្ឈមណ្ឌលសាមគ្គីភាព (SC)

១៩. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញា លុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (NGO-CEDAW)

១៧. សមាគមថែទាំសុខភាពគ្រួសារកម្ពុជា (RHAC)

២០. អង្គការនារីដើម្បីសន្តិភាព (WPM)

២១. អង្គការមណ្ឌលធនធានស្ត្រី (WRC)